ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

សំណុំរឿងព្រហ្មទណ្ឌ

លេខ : ៤៧

ចុះថ្ងៃទី០៦ ០៨ ៩៩

សាលដីកា

លេខ : ៣៩

ចុះថ្ងៃទី០៣ ១២ ៩៩

តាងនាមប្រជារាស្ត្រខ្មែរ

# តុលាការកំពូល

បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី០៣ខែធ្នូឆ្នាំ១៩៩៩

ដោយមានសមាសភាពក្រុមប្រឹក្សាជំនុំជំរះដូចតទៅ :

១ - ឯកឧត្តម ឌិត មុន្ទី ប្រធាន

២ - លោក ម៉ែប៉ន ស៊ិន ចៅក្រម

៣ - លោក សោម សិរីវុឌ្ឍ ចៅក្រម

៤ - លោក ប្រាក់ គឹមសាន ចៅក្រមរបាយការណ៍

៥ - លោក យស់ សូខឿន ចៅក្រម

លោក ទ៉ាន់ បូរ៉ាត ក្រឡាបញ្ជី

តំណាងមហាអយ្យការ

លោក ជួន ស៊ុនឡេង ព្រះរាជអាជ្ញា

អ្នកបកប្រែភាសា លោក លឹមសុគន្ធ

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខលេខ ៥៩ ចុះថ្ងៃទី ០២ ខែកក្កដា ឆ្នាំ ១៩៩៩របស់ ជនជាប់ចោទទាំង ៤ នាក់ ដែលប្តឹងមិនសុខចិត្តពីសាលដីកាព្រហ្មទណ្ឌលេខ ៥១ ចុះថ្ងៃទី ០៥ ខែ មិនា ឆ្នាំ ១៩៩៩ របស់សាលាឧទ្ធរណ៍ លើសេចក្តីសំរេចទាំងមូល និង សំណុំរឿងព្រហ្មទណ្ឌលេខ ៤៧ ចុះថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ១៩៩៩ របស់តុលាការកំពូល ។

១ - ជនជាប់ចោទឈ្មោះប៊ូទ្រាយីចាកបើវិល្លេ "ជាម្ចាស់បណ្តឹងសាទុក្ខ" ភេទ ប្រុស អាយុ ២៥ ឆ្នាំ ជនជាតិ នីហ្សេរីយ៉ា មុខរបរ វិស្វករ មានទីលំនៅមុនថ្ងៃចាប់ខ្លួន ផ្ទះសំណាក់ផ្សារឆាយមិច បន្ទប់លេខ ១០ សង្កាត់មនោរម្យ ខណ្ឌ ៧ មករា ក្រុងភ្នំពេញ ឪពុកឈ្មោះ ពីរី "ស" ម្តាយឈ្មោះរូស "ស" នៅលីវ ។ ក្នុងឃុំ ។

- មេធាវី លោក យូង សុខា ការពារជនជាប់ចោទ

២ - ជនជាប់ចោទឈ្មោះអាយូដែល បែលជីមីត្រូន "ជាម្ចាស់បណ្តឹងសាទុក្ខ" ភេទប្រុស អាយុ៣២ ឆ្នាំ ជនជាតិនីហ្សេរីយ៉ា របររកស៊ីវិស្វករ មានទីលំនៅមុនថ្ងៃចាប់ខ្លួន ផ្ទះសំណាក់ផ្សារឆាយមិចបន្ទប់លេខ ១០៧ សង្កាត់មនោរម្យ ខណ្ឌ៧មករា ក្រុងភ្នំពេញ ឪពុកឈ្មោះអាយូ ដេទៀ "រ" ម្តាយឈ្មោះ ថារេត "រ" ប្រពន្ធឈ្មោះខេត មានកូន ១ នាក់ ។ ក្នុងឃុំ ។

- មេធាវី លូង សុខា ការពារជនជាប់ចោទ

៣- ជនជាប់ចោទឈ្មោះស៊ុបណៃ អាប៊ីបូទ្បាយ៉ីដីមី "ជាម្ចាស់បណ្តឹងសាទុក្ខ" ភេទប្រុស អាយុ ៣៥ ឆ្នាំ ជនជាតិនីហ្សេរីយ៉ា របររកស៊ី ម្ចាស់សណ្ឋាគារ ទីលំនៅមុនថ្ងៃចាប់ខ្លួន ផ្ទះសំណាក់ផ្សារអូឡាំពិច បន្ទប់លេខ ១០៧ សង្កាត់មនោរម្យ ខណ្ឌ៧មករា ក្រុងភ្នំពេញ ឪពុកឈ្មោះម៉ែហ្វស៊ី "ស" ម្តាយឈ្មោះ មីណា "រ" ប្រពន្ធឈ្មោះអង់ហ្គី មានកូន១នាក់ៗ ក្នុងឃុំ ។

- មេធាវី លោក លូង សុខា ការពារជនជាប់ចោទ

៤- ជនជាប់ចោទឈ្មោះអូទីន អូយេ "ជាម្ចាស់បណ្តឹងសាទុក្ខ" ភេទ ប្រុស អាយុ៣៨ ឆ្នាំ ជនជាតិហ្គាណា របររកស៊ី ពាណិជ្ជករ មានទីលំនៅមុនថ្ងៃចាប់ខ្លួនផ្ទះសំណាក់ផ្សារអូឡាំពិច បន្ទប់លេខ ១០៦ សង្កាត់មនោរម្យ ខណ្ឌ៧មករា ក្រុងភ្នំពេញ ឪពុកឈ្មោះបេនស៊ិនអូខេ "ស" ម្តាយឈ្មោះបិតគ្រិស "រ" ប្រពន្ធឈ្មោះជេន អូខេ មានកូន៣នាក់ ៗ ក្នុងឃុំ ។

- មេធាវី អ្នកស្រី កែវ គឹមលាន

- ត្រូវចោទពីបទ រក្សាទុកសារធាតុគ្រឿងញៀននិងប្រើប្រាស់លិខិតក្លែងបន្លំ ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃទី០៧ខែកញ្ញា ឆ្នាំ ១៩៩៦តាមបញ្ញត្តិមាត្រា ៣២-៣៣-៤៧ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនច្បាប់អន្តោប្រវេសន៍ និងច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

- តាមរបាយការណ៍របស់ការិយាល័យប្រឆាំងគ្រឿងញៀន នៃស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញបានបញ្ជាក់ថា កាលពីថ្ងៃទី៦-៩-៩៦ វេលាម៉ោង១៧ មានជនជាតិស្បែកខ្មៅ ៤នាក់ ស្នាក់នៅផ្ទះសំណាក់ផ្សារអូឡាំពិច កំពុងពិភាក្សាគ្នារឿងជួញគ្រឿងញៀនទៅលាក់ទុកផ្ទះរបស់ខ្លួន ៗ លុះព្រឹកឡើងថ្ងៃទី៧-៩-៩៦ វេលាម៉ោង៥ ,៣០នាទី មន្ត្រីប៉ូលីសធ្វើការចាប់ខ្លួនជនល្មើសឈ្មោះអូទីនអូយេ នៅមុខវត្ត លង្ការ ឆែកឆេរ បានគ្រឿងញៀនតែម្តង ។

- បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការអមតុលាការក្រុងភ្នំពេញ ថា: ជនជាប់ចោទឈ្មោះអូទីន អូយេ អាយ៉ូ ដែលប៊ែរឌីមីហ្សុន ស៊ុបណៃ អាប៊ីបូទ្បាយដីមី ពីបទ: ជួញគ្រឿងញៀន និងឈ្មោះប៊ូទ្បាយ៉ី ចាកប៊ែវិល ពីបទ:ជួញគ្រឿងញៀន ក្លែងលិខិតឆ្លងដែននិងប្រើប្រាស់លិខិតឆ្លងដែន ក្លែងក្លាយ ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃទី ៧-៩-១៩៩៦ ។

- បានឃើញសាលក្រមព្រហ្មទណ្ឌលេខ ៨១ "ង" ចុះថ្ងៃទី០៧-១០-១៩៩៧ របស់តុលាការក្រុងភ្នំពេញ ដែលមានសេចក្តីសំរេចដូចតទៅ :

១- កែប្រែបទចោទលើឈ្មោះ

- អូទីន អូយេ
- អាយ៉ូដែល ប៊ែរឌីមីហ្សុន
- ស៊ុបណៃ អាប៊ីបូទ្បាយដីមី

...../....

ពីបទៈ ជួញដូរគ្រឿងញៀន ទៅជាបទៈរក្សាទុកសារធាតុញៀន តាមមាត្រា ៣៣ នៃច្បាប់ ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

២ - អោយឈប់ពីការចោទប្រកាន់លើឈ្មោះ ប៊ូឡាយីចាករ៉ែបិវណូ ពីបទជួញដូរនិងថែរក្សាទុកគ្រឿងញៀន តាមមាត្រា ៣៣ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

៣ - ផ្តន្ទាទោសឈ្មោះ

- ភូទីន ភូយេ ក្រាយូដែល ប៉ែលដឺម៉ុ ហេស៊ុន ស៊ុប ណែល អាប៊ីបូឡាយ៉ាមី ដាក់ពន្ធនាគារកំណត់ ១០ ឆ្នាំ គិតពីថ្ងៃឃុំខ្លួនទី១០ - ៥ - ១៩៩៦ ពីបទ ប្រើប្រាស់លិខិតឆ្លងដែនក្លែងក្លាយ បន្លំចូលមកព្រះរាជាណាចក្រកម្ពុជា ពុំមានច្បាប់អនុញ្ញាត តាមបញ្ញត្តិមាត្រា ៤៧ ច្បាប់ព្រហ្មទណ្ឌអន្តរកាល និង មាត្រា ៣២ ច្បាប់អន្តោប្រវេសន៍ ។

៤ - បណ្តេញទណ្ឌិតខាងលើចេញពីព្រះរាជាណាចក្រកម្ពុជា បន្ទាប់ពីបានអនុវត្តទោសរួច តាមមាត្រា ៦០ ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀននិងមាត្រា ៣៤ ច្បាប់អន្តោប្រវេសន៍ ។

៥ - ប្រកាសទទួលស្គាល់ថា លិខិតឆ្លងដែនលេខរប៉ ០២២០៨៤៥៦ ដែលមានឈ្មោះ ប៊ូឡាយី ចាកប៊ិវណូ ពិតជាលិខិតសាធារណៈក្លែង ចាប់ពីសេចក្តីសំរេចចូលជាស្ថាពរ ។

៦ - វត្ថុតាងមាន :

ក - ម្សៅ ហេរ៉ូអ៊ីន ចំនួន ៣ កញ្ចប់ រុក្ខជាតិកញ្ឆាចំនួន ១ កញ្ចប់ ត្រូវរឹបអូសនិងបំផ្លាញចោល ។

ខ - លិខិតឆ្លងដែនលេខរប៉ ០២២០៨៤៥៦ ដែលមានឈ្មោះ ប៊ូឡាយី ចាកប៊ិវណូ ជាម្ចាស់ ត្រូវរឹបអូស និងប្រគល់ឱ្យក្រសួងការបរទេសនៃព្រះរាជាណាចក្រកម្ពុជា នៅពេលសាលក្រមចូលជាស្ថាពរ ។

គ - លិខិតឆ្លងដែន ៤ ច្បាប់ ប្រាក់ដឺហ្សីម៉ាចំនួន ៣៥០ កាក់ម្ហូប២០ ប្រាក់ ៣ ដុល្លា អង្គលីខៀវ ០១ ឆ្នាំងអ៊ុតបាះកង់០១ សៀវភៅអាន៤ ស្បែកជើង ៣ អាវ៥ ខោវែង៦ ខោខ្លី៣ កាបូបខ្មៅធំ១ កាបូបហៅចៅ០១ នាមប័ណ្ណ១ ត្រូវរឹបអូស និងប្រគល់អោយសាមីម្ចាស់ត្រឡប់វិញ ដើម្បីកាន់កាប់ជាកម្មសិទ្ធិដូចដើមវិញ ។

៧ - សាលក្រមនេះជំនុំជំរះនិងប្រកាសជាសាធារណៈចំពោះមុខជនជាប់ចោទ សំរេចបើកផ្លូវប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

- បានឃើញបណ្តឹងឧទ្ធរណ៍លេខ ១៥ "ង" ចុះថ្ងៃទី១៨ - ១១ - ១៩៩៧ របស់ឈ្មោះជនជាប់ចោទទាំងបួន តវ៉ាពីសាលក្រមព្រហ្មទណ្ឌលេខ ៨១ "ង" ចុះថ្ងៃទី០៧.១០.១៩៩៧ របស់តុលាការក្រុងភ្នំពេញ លើសេចក្តីសំរេចទាំងមូល ។

- បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍សំរេចថា : សូមរក្សាការចោទប្រកាន់លើជនជាប់ចោទទាំង៤ ទុកនៅដដែល ។

- បានឃើញសាលដីកាព្រហ្មទណ្ឌលេខ៥១ចុះថ្ងៃទី ៥ ខែមិនា ឆ្នាំ ១៩៩៨ របស់

សាលាឧទ្ធរណ៍ដែលមានខ្លឹមសារសំរេចដូចតទៅ ៖

១ - ទទួលពាក្យបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី១៨ - ១១ - ១៩៥៧ របស់ជនជាប់ចោទឈ្មោះ អូទីន អូយេ ភ្រាយ៉ូដែល វ៉ែលដឺមីហេស្រ៊ិន ស៊ុបវ៉េលអាប៊ីប៊ូទ្រាយដឺមី ប៊ូទ្រាយី ចាកបេីរ៉ៃ្យ ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយទាស់ទុកនឹងគតិច្បាប់ ។

២ - តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ៨១ ង ចុះថ្ងៃទី ០៧ - ១០ - ៥៧ របស់តុលាការក្រុងភ្នំពេញ ទុកជាបានការ ។

៣ - សាលដីកាទេះ ទំនុំជំរះនៅថ្ងៃទី២៦ - ២ - ៥៨ ចំពោះមុខជនជាប់ចោទទាំងអស់ មេធាវីការពារជនជាប់ចោទ និងប្រកាសជាសាធារណៈនៅថ្ងៃទី៥ - ៣ - ៥៨ ចំពោះមុខមេធាវី លោកកើត វិណ្ណារ៉េត ឈឹម សារី កញ្ញាំងមុខមេធាវីម៉ៅ សំវុទ្ធារី និងជនជាប់ចោទទាំងអស់ ដែលចាត់ទុកជាចំពោះមុខ បើកផ្លូវសាទុក្ខក្នុងកំណត់ច្បាប់ ។

- បានឃើញបណ្តឹងសាទុក្ខលេខ ៥៥ ចុះថ្ងៃទី ២ - ០៧ - ១៩៥៨ របស់ជនជាប់ចោទទាំងអស់ ប្តឹងតវ៉ាពីសាលដីកាព្រហ្មទណ្ឌលេខ៥១ ចុះថ្ងៃទី៥ ខែមិនា ឆ្នាំ ១៩៥៨ របស់សាលាឧទ្ធរណ៍ លើសេចក្តីសំរេចទាំងមូល ។

- បានស្តាប់វេទ្យាការ រណ៍របស់ចៅក្រមរបាយការណ៍

- បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមតុលាការកំពូលថា ៖ តុលាការថ្នាក់ក្រោមអនុវត្ត ពុំត្រឹមត្រូវតាមច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌនិងច្បាប់ព្រហ្មទណ្ឌអន្តរកាល ៖ មហាអយ្យការអមតុលាការកំពូលសូមធ្វើសេចក្តីសន្និដ្ឋានដូចខាងក្រោម ៖

សាលដីកាព្រហ្មទណ្ឌលេខ ៥១ចុះថ្ងៃទី០៥ - ០៣ - ៥៨ របស់សាលាឧទ្ធរណ៍សំរេចមានលក្ខណៈខុសឆ្គងទាំងទំរង់និងគតិច្បាប់ ហេតុនេះសូមក្រុមប្រឹក្សាជំនុំជំរះមេត្តាពិនិត្យ និងសំរេច ។

- បានស្តាប់ចម្លើយជនជាប់ចោទឈ្មោះប៊ូទ្រាយីចាកបេីរ៉ៃ្យថា ៖ ឡាន់ដ្ឋ័របស់ខ្ញុំនៅប្រទេសថៃ ហើយខ្ញុំប្រើឡានដ្ឋ័របស់មិត្តខ្ញុំ ដើម្បីការពារខ្លួននៅប្រទេសថៃ ខ្ញុំបានរាយការណ៍ប្រាប់ស្ថានទូតអាល់ឺម៉ង់រួចហើយ កាលដែលខ្ញុំបាត់ឡានដ្ឋ័រនោះ ខ្ញុំចូលមកកម្ពុជាគ្មានបំណងអ្វីទេ មូលហេតុដោយបាត់ឡានដ្ឋ័រជិតផុតកំណត់ លុះមកដល់កម្ពុជាបាន៤ថ្ងៃក៏ត្រូវប៉ូលីសចាប់ខ្លួនតែម្តង ។ខ្ញុំសុំអង្វរសូមពរសុំនៅក្រៅឃុំ ។

- បានស្តាប់ចម្លើយជនជាប់ចោទឈ្មោះវ៉ែលដឺមីហេស្រ៊ិនស៊ុន ថា ៖ គេចាប់ខ្លួនខ្ញុំនៅថ្ងៃទី១០ - ៦ - ៥៦ នៅពេលខ្ញុំកំពុងអង្គុយមើលទូរទស្សន៍នៅក្នុងបន្ទប់ទទួលភ្ញៀវនៃអូតែល ខ្ញុំពុំដឹងខ្លួនថាប៉ូលីសចាប់ខ្លួនរឿងអ្វីទេ ប៉ូលីសបានចូលទៅឆែកឆេរបន្ទប់របស់ខ្ញុំ ប៉ុន្តែខ្ញុំពុំបាននៅក្នុងបន្ទប់នោះទេ ប៉ូលីសចោទថាខ្ញុំរក្សាទុកគ្រឿងញៀន ប៉ុន្តែនៅក្នុងខ្លួនខ្ញុំនិងក្នុងបន្ទប់របស់ខ្ញុំ គ្មានគ្រឿងញៀនទេ ។ ខ្ញុំសុំអង្វរសូមពរសុំនៅក្រៅឃុំ ។

- បានស្តាប់ចម្លើយជនជាប់ចោទឈ្មោះស៊ុបវ៉េលអាប៊ីប៊ូទ្រាយដឺមីថា ៖ គេចាប់ខ្លួនខ្ញុំនៅផ្ទះសំណាក់ឆាយអ៊ិច ខ្ញុំពុំដែលស្គាល់អាភៀនទេ គេចោទប្រកាន់ខ្ញុំដោយគ្មានភស្តុតាង

ខ្ញុំចូលមកកម្ពុជា ដើម្បីសុំវីសា ទៅប្រទេសជប៉ុន ដែលស្ថានទូតមិនទាន់ឆ្លើយតប ។ខ្ញុំសំណូមពរសូមឱ្យចៅក្រមជួយដោះស្រាយខ្ញុំផង ព្រោះខ្ញុំត្រូវគេចោទប្រកាន់ទេ ។

- បានស្តាប់ចម្លើយជនជាប់ចោទឈ្មោះ អូទីន អូយេ ថា: ខ្ញុំចូលមកកម្ពុជានៅថ្ងៃទី០៨-៦ ១៩៩៦ ដើម្បីធ្វើវីសា បន្តទៅហុងកុងវិញ ខ្ញុំមានមុខរបរនៅហុងកុង គឺលក់ថ្នាំសត្វល្អិត នៅពេលគេចាប់ខ្លួនខ្ញុំមានជនជាតិកម្ពុជាម្នាក់បានយកគ្រឿងញៀន មកដាក់និងចង្កេះខ្ញុំ គេចង់ធ្វើបាបខ្ញុំ ។ ខ្ញុំសំណូមពរសុំនៅក្រៅឃុំ ។

- បានស្តាប់លោកមួង សុខា មេធាវីការពារឱ្យជនជាប់ចោទបួនសន្និដ្ឋានថា: នៅពេលដែលប៉ូលីសចាប់ខ្លួនកូនក្តីខ្ញុំ គឺពុំមានលិខិតស្នាមអ្វីទេ ហើយគ្រឿងញៀនក៏ពុំមានដែរ ពេលប៉ូលីសចូលទៅ ឆែកឆេរនៅក្នុងបន្ទប់ក៏ពុំមានភស្តុតាងអ្វីទាំងអស់ ។

ដូច្នេះសូមតុលាការមេត្តាពិនិត្យពិចារណានិងសូមតុលាការដោះលែងកូនក្តីរបស់ខ្ញុំអោយមានសេរីភាពតទៅ ។

- បានស្តាប់អ្នកស្រីកែវ គឹមសាន មេធាវីការពារលោក អូទីនអូយេ សន្និដ្ឋានថា: សាលាឧទ្ធរណ៍ធ្វើខុសនីតិវិធី ជំនុំជំរះនៅថ្ងៃទី២៦-០២-១៩៩៩និងប្រកាសសាលដីកានៅថ្ងៃទី០៥-៣-១៩៩៩ ប៉ុន្តែពុំមានវត្តមានកូនក្តីខ្ញុំទេ គឺកំបាំងមុខអូទីនអូយេនិងមេធាវី ក្រោយពីប្រកាសសាលដីការួចហើយ សាលាឧទ្ធរណ៍ ពុំបានជូនដំណឹងអំពីសាលដីកាកំបាំងមុខដល់ជនជាប់ចោទនិងមេធាវីដែរ ។ ហេតុនេះសូមតុលាការមេត្តាពិនិត្យពិចារណាដោយក្តីអនុគ្រោះ ។

- បានស្តាប់សេចក្តីសន្និដ្ឋានបន្ថែមរបស់មហាអយ្យការថា: គ្មានយោបល់បន្ថែម

- ក្រោយពីបានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

- ក្រោយពីបានស្តាប់ចម្លើយដោះសាររបស់ជនជាប់ចោទសេចក្តីសន្និដ្ឋានការពាររបស់មេធាវីជនជាប់ចោទ .

- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុ លា កា រ កំ ពូ ល

- យល់ឃើញថា បណ្តឹងសាទុក្ខចុះថ្ងៃទី ២២-៦-៩៩ របស់ជនជាប់ចោទឈ្មោះ អូទីន អូយេ ប៊ូទ្យ្រាយីចាកបេិរឡូ ស៊ុបដែល អាប៊ីបូទ្យ្រាយ៉ីឌីមីនិងឈ្មោះអាយូដែលបើសជីម៉ាន្ទិន ធ្វើទៀងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះ មកជំនុំជំរះបានតាមមាត្រា ១៤ នៃច្បាប់ស្តីពីការចាត់តាំងនិងសកម្មភាពរបស់សាលាជំរះក្តី ។

- យល់ឃើញថា ការចាប់ខ្លួនជនជាប់ចោទឈ្មោះ ប៊ូទ្យ្រាយីចាកបេិរឡូ ឈ្មោះ ស៊ុបដែល អាប៊ីបូទ្យ្រាយ៉ីឌីមី និងឈ្មោះបីជីមី ពិន្ទុនស៊ុន អាយូដែល ដែលពុំមានជាបទល្មើសជាក់ស្តែង ដោយនគរបាលបង្ក្រាបគ្រឿងញៀនរាជធានីភ្នំពេញ ពុំមានដីកាពីអាជ្ញាធរតុលាការទេ គឺជាការរំលោភទៅលើមាត្រា ៣៥ និងមាត្រា ៤៧ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ ។

- យល់ឃើញថាជនជាប់ចោទទាំង០៤ នាក់ ដែលត្រូវចោទប្រកាន់ពីបទឧក្រិដ្ឋ

.......ៈ...

ពុំត្រូវបានសួរចម្លើយ នៅចំពោះមុខមេធាវីទេឡើយ ទោះនៅស្នងការដ្ឋាននគរបាល ទោះនៅមុខអយ្យការ ឬ នៅមុខចៅក្រមស៊ើបអង្កេតក្តី ដែលជាការរំលោភទៅលើមាត្រា ១០ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល និងមាត្រា ៧៦ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ ។

- យល់ឃើញថា ជនជាប់ចោទឈ្មោះអ៊ូទីន អ៊ូចេ ដែលនគរបាលកំណត់ថា ជាបទល្មើសជាក់ស្តែង បានបដិសេធចម្លើយរបស់ខ្លួន នៅស្នងការដ្ឋាននគរបាលទាំងអស់ ហើយភស្តុតាងជាសារធាតុគ្រឿងញៀន ដែលមានក្នុងកំណត់ហេតុដកហូត និងក្នុងកំណត់ហេតុចាប់ជាក់ស្តែងរបស់នគរបាល មានចំនួននិងគុណភាពខុសគ្នា ហើយសំអាងបែបនេះ តុលាការពុំអាចទទួលយកថាជាការពិតបានឡើយ ។

- យល់ឃើញថា ក្នុងការឆែកឆេរ បន្ទប់ស្នាក់នៅរបស់ជនជាប់ចោទទាំងអស់ ពុំមានដីកាពីអាជ្ញាធរតុលាការទេ ហើយក៏ពុំបានធ្វើនៅចំពោះមុខសាក្សី ឬជនជាប់ចោទឡើយ ដែលជាការរំលោភទៅលើមាត្រា ១៨, ១៩ និង មាត្រា ២០ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ដូច្នេះភស្តុតាងទាំងឡាយដែលបានមកពីអំពើរំលោភនេះ ពុំអាចយកជាការបានឡើយ។

- យល់ឃើញថា ជនជាប់ចោទឈ្មោះ ប៊ូឡាយី ចាកបេវិញ្ញូ បានប្រើលិខិតឆ្លងដែនរបស់អ្នកដទៃ ប៉ុន្តែពុំបានក្លែងលិខិតឆ្លងដែនទេឡើយ ដូច្នេះពុំត្រូវបានចោទប្រកាន់ពីបទប្រើប្រាស់លិខិតឆ្លងដែនក្លែងក្លាយតាមបញ្ញត្តិមាត្រា ៤៧ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល និង មាត្រា ៣២ នៃច្បាប់អន្តោប្រវេសន៍ទេឡើយ ប៉ុន្តែតាមមាត្រា ២៩ នៃច្បាប់អន្តោប្រវេសន៍ ជនរូបនេះត្រូវបណ្តេញចេញពីព្រះរាជាណាចក្រកម្ពុជា ក្រោយពីបានអនុវត្តទណ្ឌកម្មរួចហើយ ។

- យល់ឃើញថា ពុំមានភស្តុតាងជាក់បន្ទុកគ្រប់គ្រាន់ថា ជនជាប់ចោទឈ្មោះ អ៊ូទីន អ៊ូចេ ឈ្មោះ ស៊ីបប៉េល អាបីបូឡាអ៊ីដីមី និង ឈ្មោះ អាយូដែល ប៊ិលឌីមីហ៊្ន មានពិរុទ្ធភាពពីបទ រក្សាទុកសារធាតុគ្រឿងញៀន ដែលត្រូវផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣២ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងថាជនជាប់ចោទឈ្មោះ ប៊ូឡាយីចាកបេវិញ្ញូ មានពិរុទ្ធភាពពីបទប្រើប្រាស់លិខិតឆ្លងដែន ក្លែងក្លាយ ដែលត្រូវផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤៧ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល និងមាត្រា ៣២ នៃច្បាប់អន្តោប្រវេសន៍ ទេឡើយ ដែល តាមមាត្រា ២២២ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ តុលាការកំពូល គប្បីសំរេចអោយជនជាប់ចោទរួចខ្លួន ។

- យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ ៥១ ចុះថ្ងៃទី ០៥-៣-៩៩ របស់សាលាឧទ្ធរណ៍ ដែលបានសំរេចសេចក្តីមកនេះ មានការខុសឆ្គងទាំងទំរង់ ទាំងគតិច្បាប់ ។

## ហេតុដូច្នេះ

## វិនិច្ឆ័យ សេចក្តី ចំពោះមុខជនជាប់ចោទ

១- ទទួលបណ្តឹងសាទុក្ខ ចុះថ្ងៃទី ២២-៦-៩៩ របស់ជនជាប់ចោទឈ្មោះ អ៊ូទីនអ៊ូចេ ឈ្មោះ ប៊ូឡាយីចាកបេវិញ្ញូ ឈ្មោះ ស៊ីបប៉េល អាបីបូឡាអ៊ីដីមី និងឈ្មោះ ...

អាយូរ៉េស រ៉ឺប៊ែនដីមីហ្គ្រូនអាជីមី ទុកចាំត្រឹមត្រូវតាមទំនង និង គតិច្បាប់ ។

២ - ទុកជាមោឃៈសាលដីកាព្រហ្មទណ្ឌលេខ ៥១ ចុះថ្ងៃទី០៥ - ៣ - ៩៥ របស់សាលាឧទ្ធរណ៍ ទាំងមូល ដោយឥតបង្អង់ ។

៣ - សំរេចអោយជនជាប់ចោទឈ្មោះ អ៊ូទីន អ៊ូយេ , ប៊ិទ្យាជីចាករប៊ិរញ្ញ ស៊ុបរ៉ែយ អាប៊ីបូទ្យាជីមី និងឈ្មោះ អាយូរ៉េស រ៉ឺប៊ែនដីមីហ្គ្រូ រួចខ្លួនពីបទចោទ ។

៤ - ដោះលែងជនជាប់ចោទទាំង០៤ នាក់ ខាងលើពីការឃុំឃាំង ប្រសិនបើជនទាំង ០៤ នាក់នេះ ពុំមានជាប់ពីបទល្មើសផ្សេងទៀតទេ ។

៥ - បណ្តេញជនជាប់ចោទឈ្មោះ ប៊ិទ្យាជីចាករប៊ិរញ្ញ ចេញពីព្រះរាជាណាចក្រកម្ពុជា ។

៦ - លិខិតឆ្លងដែន០៤ ច្បាប់ ប្រាក់ នីហ្សេរីយ៉ាចំនួន ៣៥០ កាក់ម្ពូ ២០ ប្រាក់៣ ដុល្លា អង្គណីខៀវ១ ឆ្នាំងអ៊ីតប៉ះកង់០១ សៀវភៅអាន០៤ ស្បែកជើង៣ អាវ៩ ខោវែង៦ ខោខ្លី៣ កាបូបខ្មៅធំ១ កាបូបហោប៉ៅ១ នាឡិកា១ ត្រូវប្រគល់អោយម្ចាស់ទ្រព្យវិញ ។

៧ - សាលដីកានេះប្រកាសនាសវនាការជាសាធារណៈ នៅថ្ងៃ០៣ខែធ្នូ ឆ្នាំ ១៩៩៥ ។